**SPRING PARKS PRIMARY SCHOOL**
*Learning and Growing - Safety - Together*

**West Campus - Administration**
24 Erica Street, Springvale 3171 ☎ 9546 6402 🖷 9547 2763

**Valley Campus**
27-39 Clarke Road, Springvale South 3172 ☎ 9547 3222 🖷 9558 4891
✉ spring.parks.ps@education.vic.gov.au springparksps.vic.edu.au

គោរព | ចូលរួម | លទ្ធផល | សហគមន៏ | សង្ឃឹម



## កិច្ចជួបជុំរវាងមាតាបិតានិងគ្រូ

ប្រសិនជាមាតាបិតាបានផ្ញើប័ណ្ណសំណូមពរមកប្រជុំនឹងគ្រូរបស់កុមារ,លោកអ្នកនឹងបានទទួលប័ណ្ណបញ្ជាក់ម៉ោងមកប្រជុំពិតប្រាកដក្នុងពេលឆាប់ៗនេះ។សូមពិនិត្យមើលថង់របស់កុមារអំពីប័ណ្ណបញ្ជាក់ម៉ោងប្រជុំ។ ក៏ប៉ុន្តែប្រសិនជាលោកអ្នកដោយហេតុផលអ្វីមួយប្រាថ្នាចង់ប្តូរថ្ងៃឬម៉ោងណាត់ជួប,សូមទាក់ទងនឹងការិយាល័យសាលាដើម្បីឲ្យបុគ្គលិកការិយាល័យព្យាយមរកថ្ងៃឬម៉ោងជំនួសជូនប្រសិនជាមាន។ យើងខ្ញុំសង្ឃឹមថានឹងបានឃើញគ្រួសារមករួមប្រជុំឲ្យបានច្រើនក្នុងថ្ងៃពុធទី៨/៣ មកនេះ។សូមដើរត្រង់ទៅថ្នាក់រៀនរបស់កុមារដែលជាកន្លែងប្រជុំ។ នេះជាថ្ងៃរៀនធម្មតាព្រោះមានគ្រូឯកទេសនៃសាលាមកមើលកុមារនៅពេលល្ងាច។

## កំណត់ប្រចាំថ្ងៃ:: 27/2/2023

២៧/២:ពេលរៀនអំពីសុវត្ថិភាពក្នុងការប្រើអ៊ិនធើណែត សំរាប់មាតាបិតានៅសាខាខាងលិច: ម៉ោង៩:១៥ព្រឹក
កិច្ចប្រជុំនៃក្រុមប្រឹក្សាសាលា:ម៉ោង៦ល្ងាច
២៨/២: ការស្រង់ចំនួនប្រជាជន
០១/៣: កិច្ចប្រជុំនៃកុមារត្រូវការគាំទ្រពិសេស៩SSG) សាខាខាងលិច
០២/៣: គោរពទង់ជាតិ:ម៉ោង៣: ស្វាគមន៏អ្នករាល់គ្នា
០៨/៣: ជួបពិភាក្សារវាងមាតាបិតានិងគ្រូ: ពីម៉ោង២:៣០ល្ងាច
១០/៣: គោរពទង់ជាតិ:ម៉ោង៣:ស្វាគមន៏អ្នករាល់គ្នា
១៣/៣: បុណ្យការងារ:សំរាក១ថ្ងៃ

## កិច្ចប្រជុំនៃកុមារដែលទទួលកាតគាំទ្រជាពិសេស:

បើកូនលោកអ្នកបានទទួលមូលនិធិសំរាប់គាំទ្រពីកម្មវិធី PSD ,លោកអ្នកនឹងមានពេលមកប្រជុំដោយឡែកជាមួយMrs Harry ឬខ្ញុំផ្ទាល់ ហើយនឹងគ្រូរបស់កុមារ។ សាខាវ៉ាល្លីនឹងមានកិច្ចប្រជុំរបស់ខ្លួននៅថ្ងៃពុធទី១ខែមិនា, ឯសាខាខាងលិចគឺនៅថ្ងៃច័ន្ទទី៦ខែមិនា។លោកអ្នកក៏បានជូនពេលម៉ោងមកប្រជុំរួចហើយ,តែប្រសិនជាត្រូវការផ្លាស់ប្តូរ, សូមទាក់ទងនឹងការិយាល័យហើយសួររក Mr Tran.

## សំណួរសុខភាពពីគិលានុបដ្ឋាសាលា (School Nurse Questionnaire):

ធម្មតាគិលានុប្បដ្ឋានឹងផ្តល់សំណួរសុខភាពដល់កុមារថ្នាក់មូលដ្ឋាននៅត្រីមាសទី១រៀងរាល់ឆ្នាំ,ក៏ប៉ុន្តែឆ្នាំនេះសាលាយើងនឹងចាត់ចែងព្រឹត្តិការណ៏ Glasses for Kids នៅត្រីមាសទី២,ហើយនឹង Smile Squad ដែលជាសេវាខាងពិនិត្យភ្នែកនិងធ្មេញសំរាប់កុមារ។កិច្ចការនេះបានឧបត្ថម្ភថវិការពីក្រសួងអប់រំ។ដូច្នេះហើយបានជាប័ណ្ណសំណួរសុខភាពរបស់កុមារនឹងត្រូវបានប្រគល់ជូននៅត្រីមាសទី៣។ ពត៏មានបន្ថែមអំពីព្រឹត្តិការណ៏ដ៏រំភើបនេះនឹងជូននៅចុងត្រីមាសនេះ។

## Playgroup នៅសាខាខាងលិច (ការលេងសប្បាយសំរាប់កុមារមិនទាន់គ្រប់អាយុមករៀន)

បានចាប់ផ្តើមកាលពីថ្ងៃអង្គារមុននៅសាខាខាងលិច។ឆ្នាំនេះ,នឹងចាប់ផ្តើមលេងពីម៉ោង១០:០០-១២:០០ព្រឹកជាមួយនឹងអ្នកដឹកនាំការលេងមាននាមថា Ayan ហើយគាត់សង្ឃឹមថានឹងបានជួបមាតាបិតាដែលមានកូនតូចៗមកលេងរាល់អាទិត្យ។ការលេងនេះ, មិនចាំបាច់ថាកុមរនោះត្រូវរៀននៅសាលាយើងនោះទេ,សូមអញ្ជើញមិត្តភក្តិដទៃមកលេងជាមួយ!

## បោះជំរុំឆ្នាំ២០២៣:

ថ្នាក់ទី៥និង៦នឹងបោះជំចំនួន៣ថ្ងៃដើម្បីទៅលេងនិងផ្សងព្រេងជាមួយនឹងគ្រូរបសកុមារនៅ Camp Gundiwindi ក្នុងថ្ងៃទី៣,៤និង៥ ខែមេសា។ គ្រួសារទាំងឡាយបានបង់ប្រាក់ជិតអស់ទៅហើយ,តែបើមានគ្រួសារណាជួបប្រទះនឹងការលំបាកខាងថវិការ,សូមមកជួបនឹង Mrs Harry ឬខ្ញុំដើម្បីពិភាក្សាអំពីគំរោងការបង់ប្រាកឲ្យកុមារទៅបោះជំរុំ។ បើគ្រួសារណាមានកូនពីរទៅបោះជមរំជាមួយគ្នា,សាលានឹងចុះថ្លៃជូនដូចគ្រួសារមួយចំនួនបានទទួលការចុះថ្លៃនេះ។ យើងខ្ញុំដឹងថានេះជាព្រឹត្តិការណ៏សាលាមួយដែលគ្រួសារត្រូវចំណាយប្រាក់យ៉ាងច្រើន, តែយើងខ្ញុំរីករាយនឹងជួយតាមលទ្ធភាពរបស់សាលា។

សូមឲ្យពីរសប្តាហ៏ទៅមុខនេះប្រកបដោយក្តីសុខនិងសប្បាយ។

Julie Fisher

នាយកសាលា

សាលាយើងមានក្តីសោមនស្សជាគូរភាគីនឹង : **Ardoch, IKEA, Woodleigh School, Officeworks and Resilience Project**

## ការឈប់សំរាកដោយបានធ្វើការយូរឆ្នាំ:

បុគ្គលិកទាំងឡាយនឹងបានទទួលការឈប់សំរាកក្នុងក្របខ័ណ្ឌការងារយូរឆ្នាំក្រោយពីធ្វើការបាន៧ឆ្នាំ។ខ្ញុំសូមជូនដំណឹងដល់សហគមន៏សាលាយើងថា Mrs Rakic នឹងឈប់សំរាកក្នុងត្រីមាសទី២ទាំងមូលក្នុងក្របខ័ណ្ឌការងារយូរឆ្នាំ,តែយើងខ្ញុំក៏បាន Mrs Dounis មកជំនួសក្នុងត្រីមាសទី២នេះដែរ។

យើងខ្ញុំសំណាងណាស់ដោយបានគ្រូ ប្រកបដោយការពិសោធន៏ដូច Mrs Dounis នេះដែលមានចិត្តមកបង្រៀនជំនួសក្នុងរយៈពេលនៃត្រីមាសទី២ទាំងមូល។សូមអរគុណ Mrs Dounis .

ព្រមពេលជាមួយគ្នានេះ, Mrs Ary ក៏នឹងសំរាកចាប់ពីថ្ងៃទី១២/៥ រហូតដល់ថ្ងៃចុងក្រោយនៃត្រីមាស។សាលាមិនទាន់មានគ្រូជំនួស, តែកំពុងស្វែងរក,ហើយយើងខ្ញុំនឹងជូនដំណឹងដល់មាតាបិតាភ្លាមៗប្រសិនជារកបានគ្រូជំនួស។

Mrs Lyons ក៏នឹងឈប់សំរាក នៅពីរសប្តាហ៏ចុងក្រោយនៃត្រីមាសទី១និងពីរសប្តាហ៏ដំបូងនៃត្រី មាសទី២។សាលាបានផ្តល់ការងារឲ្យគ្រូបង្រៀនសិល្បៈនាមJo Stewart ពីភ្នាក់ងារ anzuk ដែលធ្លាប់បានបង្រៀនសិល្បៈនៅសាលាយើងពី ដើម។ទីបំផុត Mrs Wirrick ក៏នឹងឈប់សំរាកនៅសប្តាហ៏ចុងក្រោយនៃត្រីមាសទី១ហើយនឹងសប្តាហ៏ដំបូងនៃត្រីមាសទី២.

## ព្រឹត្តិការណ៏សហគមន៏សាលា

ស្វែងរកអាថ៌កំបាំង

**តើអ្នកណាជាអ្នកលួចនំពីកែវដាក់នំ**



យើងត្រូវការជំនួយពីលោកអ្នកដើម្បីដោះស្រាយអាថ៌កំបាំងនេះ!

ពេលល្ងាចដ៏រីករាយនិងដ៏សកម្មសំរាប់គ្រួសារទាំងមូល

កុមាររួមជាក្រុមជាមួយនឹងឪពុកម្តាយរបស់ខ្លួនស្វែងរកតម្រុយនៅទីធ្លាសាលា។

ថ្ងៃពុធ ទី ២៩ ខែ មិនា នៅសាខខាខាងលិច
ពីម៉ោង៣:៣០-៤:០០ល្ងាច- សាច់ក្រកអាំងឥតគិតថ្លៃ
ពីម៉ោង៤:០០-៥:០០លង្ងាច- ល្បែង "តើអ្នកណាជាអ្នកលួចនំក្នុងកែវ "

**មានរង្វាន់- លេងសប្បាយ**

## កាលវិភាគនៃការប្រឡងសាក NAPLAN

| ថ្ងៃ: **Date:** | | ពិធីប្រឡងសាក **NAPLAN** |
|---|---|---|
| ថ្ងៃពុធ | ទី១៥/៣ | សរសេរ Writing |
| ថ្ងៃព្រហស្បត៏ | ទី១៦/៣ | អាន Reading |
| ថ្ងៃសុក្រ | ទី១៧/៣ | អនុញ្ញាក្នុងការសរសេរ |
| ថ្ងៃចន្ទ | ទី២០/៣ | លេខគណិត : Numeracy |

កុមារថ្នាក់ទី៣និងទី៥ទាំងឡាយនឹងចូលរួមការប្រឡងសាកដូចបានបញ្ជាក់ពីលើ,លុះត្រាតែមានការលើកលែងពិសេស។បើកុមារណាមួយមិនបានមកប្រឡងទេ,សាលានឹងចាត់ចែងឲ្យប្រឡងនៅថ្ងៃក្រោយឲ្យតែការប្រឡងនេះត្រូវបានបញ្ចប់មុនថ្ងៃទី២៧ ខែ មិនា។លំដាប់ធ្លាប់នៃការប្រឡងមិនអាចផ្លាស់ប្តូរបានព្រោះនេះបានសម្រេចដោយក្រសួងអប់រំ។ថ្នាក់ទី៣នឹងប្រឡងពីការសរសេរដោយសរសេរនឹងដៃ(អាចជារឿងនិទានឬអត្ថបទបញ្ចុះបញ្ចូល), តែថ្នាក់ទី៥ត្រូវវាយក្នុងកុមព្យូទ័ររបស់សាលា។សូមពិភាក្សាជាមួយកុមារអំពីការប្រឡងសាកនេះ ហើយត្រូវឲ្យកុមារទុកចិត្តថានេះជាផ្នែកមួយនៃការវាយតម្លៃដែលសាលាទាំងឡាយប្រមូលយកមកឲ្យដឹងពត៌មានបន្ថែមពីកុមារ។ មានកុមារមួយចំនួនព្រួយបារម្មណ៏ពីការប្រឡងនេះ,ដូច្នេះយើងខ្ញុំនឹងរួមធ្វើការជាមួយនឹងគ្រួសារដើម្បីបំបាត់ការព្រួយបារម្មណ៏នេះ។

## ថ្នាក់បំរុងសប្បាយនឹងពេលរៀនក្នុងបន្ទប់សិល្បៈ














ថ្ងៃទី២១ខែមិនា
**សាខា BANKSIA**
8-20 Janine Road,
Springvale South
(03)95464144

ថ្ងៃទី២៣ ខែ មិនា
**សាខា BANKSIA**
8-20 Janine Road,
Springvale South
(03)95464144

## រាត្រីបើក បង្ហាញ

រាត្រីបើកបង្ហាញនិងដើរមើលជុំវិញសាលា។ ពីម៉ោង ៦:៣០-៨:៣០

## ធ្វើការជ្រើសរើសអនាគតរបស់កូនលោកអ្នក។

ធនាដល់សុវត្ថិភាពអនាគតកូនលោកអ្នកនៅវិទ្យាល័យឃីបរ៉ូ

ឱកាសតែមួយគត់សំរាប់អនាគតមាតាបិតានិងសិស្សានុកំពុងស្វែងរកឱកាសរៀនសូត្រដ៏ប្រពៃបំផុតក្នុងការអប់រំនៅមធ្យមសិក្សា។មកជួបនាយកសាលានិងក្រុមគ្រូដឹកនាំនៃសិស្សមកថ្មី។ហើយរៀនមុនគេបង្អស់អំពី:

- កម្មវិធីសិក្សានិងជ្រើសរើសមុខវិជ្ជា
- កម្មវិធីគណិតនិងអាន&សរសេរដែលធ្វើឲ្យមានភាពខុសប្លែក
- កម្មវិធីតម្លើងថ្នាក់ទី៧ដ៏ថ្មីហើយខ្ពង់ខ្ពស់
- រៀនតន្ត្រីសំរាប់សិស្សគ្រប់គ្នា
- កម្មវិធី iPad & netbook (iPad & កុំមព្យូទ័រ)សំរាប់សិស្សគ្រប់គ្នា
- ឱកាសឲ្យសិស្សរួមចំណែកក្នុងកម្មវិធីដឹកនាំនិងឆ្ពោះទៅឧត្តមភាព
- ឧបករណ៍រៀនសូត្រនៃសតវត្សទី២១មាន: សិល្បៈសម្តែង,មជ្ឈមណ្ឌលវិទ្យាសាស្ត្រ,គណិតសាស្ត្រនិងបច្ចេកទេស,មជ្ឈមណ្ឌលសិល្បៈនិងបច្ចេកទេស



**KEYSBOROUGH COLLEGE**

RESPECT • EXCELLENCE • DIVERSITY

Email: keysborough.sc@education.vic.gov.au **www.keysboroughsc.vic.edu.au**

## វិធានការអំពីទូរស័ព្ទចល័ត

ដូចលោកអ្នកជ្រាបសាប់ហើយថា,នយោបាយថ្មីអំពីទូរស័ព្ទចល័ត ដែលអនុវត្តឲ្យសាលារដ្ឋវិចតូរីយ៉ាទាំងឡាយបានចាប់មានអនុភាព តាំងពីឆ្នាំ ២០២០។នយោបាយនេះតម្រូវឲ្យសិស្សត្រូវបិទ-ទុក ទូរស័ព្ទដៃរបស់ខ្លួននៅថ្ងៃរៀន។

នយោបាយនេះបានកសាងឡើងដើម្បីគាំទ្រការរៀននិងបង្រៀន, ផ្សព្វផ្សាយពីបរិយាកាសសិក្សាមួយដែលពុំមានការរំខានមិនចាំបាច់។ នយោបាយនេះកសាងឡើងក្នុងបំណងបង្កើនចលនារាងកាយនិង ទំនាក់ទំនងរវាងសិស្សនៅពេលចេញលេងឬពេលបាយថ្ងៃត្រង់។

តាមការសង្កេតក្នុងពេលជិតៗនេះបានបង្ហាញឲ្យឃើញថា,ការប្រើ ទូរស័ព្ទដៃនៅពេលរៀនបានបន្ថយ,ហើយនាយកនិងគ្រូក្នុងសាលា បានកត់សម្គាល់ឃើញពីឥតប្រយោជន៏ជាច្រើនក្នុងការអនុវត្តន៏ ន យោបាយនេះ។ក្រសួងអប់រំបានផ្សាយទំព័រគាំទ្រមាតាបិតាអំពីទូរ ស័ព្ទចល័តក្នុងសាលានៅក្នុងគេហទំព័ររបស់ក្រសួង។គេហទំព័រនេះ មានរួមទាំងតំណស្តីពីការគាំទ្រមាតាបិតា/អាណាព្យបាលអំពី សុវត្ថិភាពនៃការប្រើបច្ចេកទេសនិងការទទួលខុសត្រូវនៅផ្ទះ។

សាលាយើងមាននយាបាយអំពីទូរស័ព្ទចល័តផ្ទាល់ដោយយកលំនាំ តាមក្រសួងអប់រំរួមនឹងបរិបទរបស់សាលា។នយោបាយអំពីទូរស័ព្ទ ចល័តរបស់សាលាយើងអាចរកឃើញនៅ :

https://springparksps.vic.edu.au/wp-content/uploads/2023/02/Mobile-Phones.docx.

ខ្ញុំអំពាវនាវឲ្យគ្រួសារដែលមានកូនទើបមករៀនថ្មីៗនេះអាននយោបាយរបស់សាលាយើង,ព្រោះវាបានបញ្ជាក់ច្បាស់នូវតម្រូវការរបស់ សាលាពីបុគ្គលិក,មាតាបិតា/អាណាព្យាបាលនិងសិស្សានុសិស្ស ទាក់ទងទៅនឹងការប្រើទូរស័ព្ទចល័តនៃសិស្សក្នុងសាលា។ ខ្ញុំក៏សូមអំពាវនាវដល់គ្រួសារមានកូនទើបមករៀននៅសាលាយើង ឲ្យអនុវត្តនយោបាយទូរស័ព្ទចល័តក្នុងសាលា។បើលោកអ្នកមាន សំណួរអំពីនយោបាយនេះ,សូមទាក់ទងនឹងការិយាល័យសាលា។ សូមអរគុណ។

Julie Fisher : នាយកសាលា

## កុមារបោះក្រឡាប់នំចៀននៅថ្ងៃ ប៉ែនខេក(Pancake Day) ថ្ងៃអង្គារ






## STARS OF THE WEEK

### WEST CAMPUS

| Grade | Week 3 |
|---|---|
| FA | Thomas & Khuab |
| 1/2 A | Emily |
| 1/2 B | Mila |
| 3/4 A | Jayton |
| 3/4 B | Morokot |
| 5/6 A | |
| 5/6 B | Derreck |
| Art | |
| PE | Allen |
| Spanish | Orson |

### VALLEY CAMPUS

| Grade | Week 3 |
|---|---|
| FA | Maaki |
| 1/2 L | Acil |
| 1/2 M | Dixon |
| 3/4 L | Theo |
| 3/4 M | Joe |
| 5/6 L | Dararoth |
| 5/6 M | Jenny |
| Art | Mandy |
| PE | Harvie |
| Spanish | Alycia |